# ដាក់ពាក្យធ្វើពន្ធដើម្បីយកប្រាក់មកវិញ



អ្នកអាចមានសិទ្ធិទទួលបានលុយរាប់ពាន់ដុល្លារក្នុងការធ្វើពន្ធរបស់អ្នកពេលដែលអ្នកដាក់សុំឥណទានពន្ធលើប្រាក់ចំណូលដែលរកបានរបស់សហព័ន្ធ និងឥណទានពន្ធកុមារ

## វិធីដើម្បីទទួលបានឥណទានពន្ធរបស់អ្នក៖

1 **ចង់ដឹងថាតើអ្នក មានសិទ្ធិទទួលបានឬទេ**
ស្វែងយល់ថាតើអ្នកអាចទទួលបានលុយប៉ុន្មានដែរនៅ TaxOutreach.org/TaxCredits ។

2 **ស្វែងរកជំនួយ ធ្វើពន្ធ ដោយឥតគិតថ្លៃ**
ចូលទៅកាន់ GetYourRefund.org ឬទូរស័ព្ទទៅលេខ 800-906-9887 ទោះបីជាធម្មតាអ្នកមិនដែលដាក់ធ្វើពន្ធពីមុនក៏ដោយ។

3 **ដាក់ឯកសារ ធ្វើពន្ធ របស់អ្នក**
ទទួលបានជំនួយធ្វើពន្ធរបស់អ្នកអោយបានមុនថ្ងៃទី 15 ខែមេសា ឆ្នាំ 2024 ដោយឥតគិតថ្លៃ។

## ឯកសារអ្វីដែលត្រូវកាន់ទៅពេលណាត់ជួបធ្វើពន្ធ៖

- ❑ អត្តសញ្ញាប័ណ្ណដែលមានសុពលភាព
- ❑ ប័ណ្ណសូស្យាល់សេគួរិទី លិខិតបញ្ជាក់លេខសូស្យាល់សេគួរិទី ឬ ITIN សម្រាប់អ្នករាល់គ្នាដែលមានឈ្មោះនៅលើឯកសារធ្វើពន្ធរបស់អ្នក។
- ❑ W-2 ឬ 1099
- ❑ 1095-A
- ❑ ការជូនដំណឹងពី IRS បើមាន
- ❑ ឯកសារធ្វើពន្ធឆ្នាំ 2021 និង 2022 ប្រសិនបើអ្នកមាន
- ❑ លេខសម្ងាត់ (IP PIN) ប្រសិនបើអ្នកមាន

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ TaxOutreach.org/TaxCredits ឬទូរស័ព្ទទៅ IRS តាមលេខ 1-800-829-1040**



## សិទ្ធិទទួលបានឥណទានពន្ធលើប្រាក់ចំណូលដែលទទួលបាន (EITC) និងឥណទានពន្ធកុមារ (CTC)៖

**ប្រសិនបើអ្នកមិនមានកូន អ្នកអាចមានសិទ្ធិទទួលបាន EITC រហូតដល់ $600 ប្រសិនបើ៖**

**អាយុ៖**

អ្នកមានអាយុចន្លោះពី 25 ទៅ 64 ឆ្នាំ គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2023។

**ប្រាក់ចំណូលឆ្នាំ 2023៖**

អ្នករកបានតិចជាង $17,640 ($24,210 ប្រសិនបើដាក់រៀបការ)។

**ប្រសិនបើអ្នកមិនមែនជាពលរដ្ឋអាមេរិកទេ អ្នកអាចមានសិទ្ធិទទួលបាន ប្រសិនបើ៖**

- **EITC៖** អ្នក ប្តីឬប្រពន្ធរបស់អ្នក និងមានកូនណាមួយដែលអ្នកដាក់ឈ្មោះក្នុងឯកសារពន្ធ មានលេខសូស្យាល់សេគួរិទី (SSN) ត្រឹមត្រូវ។
- **CTC៖** កូនណាមួយដែលអ្នកដាក់ឈ្មោះមាន SSN ។ អ្នក និងប្តីឬប្រពន្ធរបស់អ្នកត្រូវតែមានលេខ SSN ឬលេខអត្តសញ្ញាណសំរាប់ធ្វើ ពន្ធរបស់បុគ្គលម្នាក់ៗ (ITIN)។

## តើខ្ញុំមានសិទ្ធិទទួលបានដែរឬទេ?

**នៅពេលធ្វើពន្ធប្រចាំឆ្នាំ អ្នកអាចជំពាក់ពន្ធតិច និងទទួលបានលុយត្រឡប់មកវិញ** ជាមួយនឹងឥណទានពន្ធលើប្រាក់ចំណូលដែលរកបាន និងឥណទានពន្ធកុមារ! ប្រសិនបើអ្នកបានធ្វើការនៅឆ្នាំ 2023 អ្នកប្រហែលជាអាចមានសិទ្ធិទទួលបានឥណទានទាំងនេះ។

**ជំនួយសាធារណៈ៖**

- ការសុំលុយឥណទានពន្ធទាំងនេះនឹងមិនផ្លាស់ប្តូរសិទ្ធិទទួលជំនួយសហព័ន្ធដូចជាជំនួយ SNAP (ហូតស្តែម), SSI, មេឌីខេដ, ជំនួយសាច់ប្រាក់ ឬជំនួយចេញថ្លៃបង់ផ្ទះរបស់អ្នកនោះទេ។
- ប្រសិនបើអ្នកសន្សំលុយដែលបានពីការធ្វើពន្ធរបស់អ្នក នោះវានឹងមិនរាប់បញ្ចូលជាដែនកំណត់ធនធាន/ទ្រព្យសម្បត្តិនៅក្នុងកម្មវិធីជំនួយដែលផ្តល់មូលនិធិពីសហព័ន្ធសម្រាប់រយៈពេល 12 ខែ បន្ទាប់ពីអ្នកទទួលបានលុយពីការធ្វើពន្ធនោះ។

## ប្រសិនបើអ្នកមានកូន អ្នកអាចមានសិទ្ធិទទួលបាន EITC និង CTC ប្រសិនបើ៖

**មានទីលំនៅ៖**

- កូនរបស់អ្នកបានរស់នៅជាមួយអ្នកអស់រយៈពេលជាងពាក់កណ្តាលនៃឆ្នាំ 2023។

**អាយុ - កូនត្រូវតែមានអាយុ៖**

- **EITC៖** 18 ឆ្នាំ ឬក្រោមនេះគិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2023 (អាយុក្រោម 24 ឆ្នាំ បើជាកូនសិស្សរៀនពេញម៉ោង ហើយអាចអាយុប៉ុន្មានក៏បានដែរបើជាកូនដែលមានពិការភាពអចិន្ត្រៃយ៍)។
- **CTC៖** 16 ឆ្នាំ ឬក្រោមនេះគិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2023។

**ប្រាក់ចំណូលសម្រាប់ឆ្នាំ 2023៖**

- **សម្រាប់ឥណទាន CTC សហព័ន្ធ** ប្រសិនបើអ្នករកបានច្រើនជាង $2,500 អ្នកអាចទទួលបានលុយឥណទានរហូតដល់ $2,000 ក្នុងកូនម្នាក់ៗ។
- **សម្រាប់ឥណទាន EITC សហព័ន្ធ** ប្រាក់ចំណូលរបស់អ្នកត្រូវតែទាបជាងដែនកំណត់ខាងក្រោម៖

| ចំនួនកូន | អ្នកនៅលីវដែលធ្វើការ ហើយមានប្រាក់ចំណូលតិចជាង៖ | អ្នករៀបការដែលធ្វើការហើយមានប្រាក់ចំណូលតិចជាង៖ | បាន EITC រហូតដល់៖ |
|---|---|---|---|
| **កូន 1 នាក់** | $46,560 | $53,120 | $3,995 |
| **កូន 2 នាក់** | $52,918 | $59,478 | $6,604 |
| **កូន 3 នាក់ឬលើសពីនេះ** | $56,838 | $63,398 | $7,430 |

### មិនទាន់យឺតពេលទេក្នុងការដាក់ពាក្យសុំឥណទានពន្ធកាលពីឆ្នាំ 2021!

**ដោយសារមានជំងឺរាតត្បាតកូវីដនេះឥណទាន EITC និងឥណទានពន្ធកុមារត្រូវបានគេបន្ត និងធ្វើឱ្យមនុស្សកាន់តែច្រើនបានទទួលវា។** ការបន្តនោះបានបញ្ចប់ហើយ ប៉ុន្តែប្រសិនបើអ្នកមានសិទ្ធិទទួលបានឥណទាន EITC ដែលបានបន្តនាឆ្នាំ 2021 ឥណទានពន្ធកុមារដែលបានបន្តឆ្នាំ 2021 ឬលុយណាមួយក្នុងចំណោមលុយបីដងដែលរដ្ឋអោយ ហើយអ្នកមិនបានទទួលនៅឡើយ នោះ មិនទាន់យឺតពេលទេ! សូមចូលទៅកាន់ TaxOutreach.org/expanded ដើម្បីស្វែងយល់បន្ថែម។